**BMI0049**

# សម្ភាសន៍ជាមួយឈ្មោះ និន នាវ ភេទស្រី អាយុ៤៦ឆ្នាំ

## មុខងារដំនាន់ខែ្មរក្រហមៈ «ធ្វើការកងចល័ត»

## មុខងារបច្ចុប្បន្នៈ «កសិករ»

## ស្រុកកំណើតនៅភូមិស្រែ ឃុំសំឡាញ់ ស្រុកអង្គរជ័យ ខេត្តកំពត

## រស់នៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

## ០០:៤៦:៥៧

## ២៥ទំព័រ

ប៊ុនថនៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអីដែរ?

នាវៈ ខ្ញុំឈ្មោះនិន នាវ ។

ប៊ុនថនៈ និន នាវ?

នាវៈ ចាស ។

ប៊ុនថនៈ អាយុប៉ុន្មានមីង?

នាវៈ អាយុ៤៦ហើយ ។

ប៊ុនថនៈ មីងមានស្រុកកំណើតនៅភូមិឃុំអីដែរ?

នាវៈ ភូមិស្រែ ឃុំសំឡាញ ស្រុកអង្គជ័យ ខេត្តកំពត ។

ប៊ុនថនៈ ភូមិអីវិញមីង?

នាវៈ ភូមិព្រះស្រែ ។

ប៊ុនថនៈ ចឹងភូមិព្រះស្រែ?

នាវៈ ចាស ។

ប៊ុនថនៈ ឃុំស្អីវិញ?

នាវៈ ឃុំសំឡាញ ។

ប៊ុនថនៈ ចឹងមីងមានបងប្អូនប៉ុន្មាននាក់?

នាវៈ ខ្ញុំមានបងប្អូន៧ទៅ៨នាក់តែស្លាប់ជំនាន់ប៉ុល ពតអស់ហើយ មាន៧នាក់នៅសល់បួននាក់ ។

ប៊ុនថន៖ ចឹងមីងកូនទីប៉ុន្មាន?

នាវ៖ កូនទី៥ មិនដឹងកូនទីប៉ុន្មានកូនទី៥ចឹងហើយ ។

ប៊ុនថន៖ ស្រូប៉ុន្មានប្រុសប៉ុន្មាន?

នាវ៖ ស្រី២ប្រុស៥តែងាប់អស់ហើយហ្នឹង ងាប់សម័យប៉ុល ពតអស់ហើយហ្នឹងណាស់ ។

ប៊ុនថន៖ បាទ ។

នាវ៖ ធ្វើទាហាន ។

ប៊ុនថន៖ ចឹងកាលនៅភូមិមានបានចូលរៀនអីទេមីង?

នាវ៖ កាលជំនាន់ដើមមានយន្តហោះទម្លាក់ខ្ញុំមានអាយុតែ៧ឆ្នាំហ្នឹង ដល់យើងរត់ទៅស្រុកគេ យើងរត់ទៅស្រុកគេទៅ ឡើងមកគេឲ្យរៀនសាលាក្នុងព្រៃនោះ ខ្លាចយន្តហោះទម្លាក់មក កាលហ្នឹងរៀនបានថ្នាក់ទី១១ជំនាន់ហ្នឹង ។

ប៊ុនថន៖ បាទ ។

នាវ៖ ថ្នាក់ទី១១ស្មើថ្នាក់ទី២យើងឥឡូវហ្នឹង កាលហ្នឹងរៀននៅក្នុងព្រៃ ។

ប៊ុនថន៖ រៀនក្នុងព្រៃ?

នាវ៖ ចាស ។

ប៊ុនថន៖ ចឹងរៀនថ្នាក់ទី១១ហើយក្រោយមីងទៅណាទៀត?

នាវ៖ ក្រោយមកខ្ញុំមកនៅម៉ាឡៃហ្នឹងឆ្នាំ៨០ ។

ប៊ុនថន៖ បាទ ។

នាវ៖ ឆ្នាំ៨០ហ្នឹងខ្ញុំរៀនបានបន្តិចៗដែរ កងកុមារនារីហ្នឹងគេឲ្យរៀនបានបន្តិចៗដែរ ចេះអាន ចេះអីទៅ ។

ប៊ុនថន៖ ចឹងមីងមកដល់ម៉ាឡៃនៅឆ្នាំណា?

នាវ៖ ឆ្នាំ៨០ខ្ញុំទៅជំរំស្រះកែវ កាលហ្នឹងកាកបាទគេយកទៅនោះ ។

ប៊ុនថន៖ បាទ ។

នាវ៖ យើងរត់ទៅដល់ដីថៃនោះឈឺ ដល់ហើយខាងកាកបាទគេយកទៅដាក់ជំរំស្រះកែវ ។

ប៊ុនថន៖ បាទ ។

នាវ៖ ដល់ចេញពីជំរំហ្នឹងមកគេយកមកដាក់នៅភូមិដូងយើងនេះ ចំការចេកនេះដល់ហើយគេ រើសកងកុមារមកនៅម៉ាឡៃនេះ តា អៀង សារីជំនាន់ហ្នឹង ។

ប៊ុនថន៖ បាទ ។

នាវ៖ ហើយបានមកនៅម៉ាឡៃនេះខាងសិល្បៈ ។

ប៊ុនថន: ចឹងនៅខាងសិល្បៈ?

នាវ: ចាស!សិល្បៈនៅម៉ាឡៃនេះ ពេលមកនៅបានមួយឆ្នាំចេញមកនៅដឹកជញ្ជូន ជញ្ជូនគ្រាប់ឲ្យគេវៃនោះ ។

ប៊ុនថន: បាទ ។

នាវ: កាលហ្នឹងទូលគ្រាប់ ឲ្យពួកទ័ពវៃ ។

ប៊ុនថន: ដឹកជញ្ជូនហ្នឹងមានការងារអីខ្លះមីង?

នាវ: ដឹកជញ្ជូនគ្រាប់យកទៅសមរភូមិ ។

ប៊ុនថន: តែមីងមានដែលឡើងវៃទេ?

នាវ: អត់ទេ ដែលតែជញ្ជូនគ្រាប់ ជញ្ជូនទឹកចឹងទៅយកទៅសមរភូមិយកទៅឲ្យគេយើងមកវិញមក ។

ប៊ុនថន: ចឹងឆ្នាំ៨០មីងមកដល់ម៉ាឡៃនេះ?

នាវ: ចាស ។

ប៊ុនថន: ឬ៧៩មីង?

នាវ: ឆ្នាំ៨០មកពីជំរំស្រះកែវមកនៅម៉ាឡៃ ។

ប៊ុនថន: ចឹងទៅនៅជំរំបានប៉ុន្មាន?

នាវ: ទៅនៅជំរំបានតិចដែរ ។

ប៊ុនថន: ដល់មួយឆ្នាំទេ?

នាវ: អត់ទេ បានបួនប្រាំខែគេឲ្យមករកម៉ែឪចឹងទៅណាស់ ។

ប៊ុនថន: បាទ ។

នាវ: ហើយយើងតូចៗចេះតែថាគោះទៅរកម៉ែឪយើងវិញក៏មកនៅម៉ាឡៃនេះមក ។

ប៊ុនថន: នៅម៉ាឡៃដំបូងមីងមកនៅណា នៅភូមិដូង?

នាវ: នៅភូមិកុដ ។

ប៊ុនថន: ភូមិអី?

នាវ: ភូមិកុដនៅខាងសិល្បៈ ។

ប៊ុនថន: តែកាលនៅម៉ាឡៃហ្នឹងមានមនុស្សនៅទេ?

នាវ: មានតែយោធាទេ មានតែកងទ័ពយុវជនយុវនារីចឹងទៅណាស់ ។

ប៊ុនថន: បាទ ។

នាវ: ប្រជាជនមិនមានទេ ។

ប៊ុនថនៈ ចឹងមឹងមកនៅហ្នឹងនៅម៉ាកង?

នារៈ ចាស!នៅម៉ាកងនារីចឹងទៅ ដូចជាកងទី១កងទី២ចឹងទៅមានគ្នា៥០នាក់ក្នុងមួយកងៗចឹងទៅ យើងធ្វើផ្ទះនៅមួយៗចឹងទៅ ។

ប៊ុនថនៈ បាទ ។

នារៈ នៅដាំបាយរួមចឹងទៅណាស់ ។

ប៊ុនថនៈ បាទ ។

នារៈ ហូបរួមបាយរួម ។

ប៊ុនថនៈ មួយកងមានគ្នាប៉ុន្មាននាក់មឹង?

នារៈ មួយកងគេមានច្រើនរាប់រយនាក់ដែរ មានកងវរៈសេនាតូចវរៈសេនាធំអីចឹងទៅណាស់ ។

ប៊ុនថនៈ បាទ ។

នារៈ តែមានមួយក្រុមមួយផ្ទះអីចឹងទៅ ។

ប៊ុនថនៈ បាទ ។

នារៈ នៅមើលជំនាន់មុនចឹង ។

ប៊ុនថនៈ បាទ!ចឹងកាលមឹងមកនៅហាត់សិល្បៈតែម្តងមឹង?

នារៈ ខ្ញុំមកនៅខាងសិល្បៈបានមួយឆ្នាំចេញពីសិល្បៈវិញ ថាដូចជាយើងរាងធំៗបន្តិចទៅណាស់ រើសចេញពីសិល្បៈហ្នឹងមកនៅដឹកជញ្ជូន ។

ប៊ុនថនៈ ចឹងនៅខាងសិល្បៈមឹងមានហាត់រៀនទេ?

នារៈ ច្រៀងគេចឹងទៅណាស់សើច... ។

ប៊ុនថនៈ ចឹងសិល្បៈមានច្រើនដូចថាមានល្ខោនមានច្រៀង?

នារៈ ទេ ជំនាន់ហ្នឹងក្រុមសិល្បៈម៉ាឡៃហ្នឹងមានតែអ្នករាំអីចឹងទៅណាស់ ។

ប៊ុនថនៈ បាទ ។

នារៈ ហើយអ្នកច្រៀងអីចឹងទៅណាស់ ។

ប៊ុនថនៈ ចឹងមឹងយកខាងទាំងពីរ?

នារៈ ខ្ញុំច្រៀងខ្ញុំមិនដែលរាំផង ។

ប៊ុនថនៈ ចឹងមឹងច្រៀងបានទេ ការហាត់ចឹង?

នារៈ ច្រៀងបានជាមួយគេជាមួយឯងយើងច្រៀងជាក្រុមណាស់ មិនមែនច្រៀងម្នាក់ៗឯងទេ ។

ប៊ុនថនៈ អត់មានឡើងច្រៀងម្នាក់ឯងទេ?

ណាវៈ អត់ទេ ច្រៀងក្រុមដូចជាគេរាំចឹងទៅ ដូចជាយើងមានគ្នា៩នាក់ចឹងមានគេឡើងរាំយើងច្រៀងចឹងទៅណាស់ ។

ប៊ុនថនៈ ច្រៀងបទអីទៅមីង?

ណាវៈ បទស្រុកពីមុនជំនាន់នោះច្រៀងបទគោះត្រឡោកអីចឹងទៅ គោះអង្រែចឹងទៅណាស់ ។

ប៊ុនថនៈ ចឹងក្រុមសិល្បៈមានច្រើនទេ មីងមានគ្នាប៉ុន្មាននាក់ទៅ?

ណាវៈ មានគ្នាច្រើនដែលមានគ្នារាប់រយនាក់ទៅ នៅភូមិកោះហ្នឹង ។

ប៊ុនថនៈ ចឹងដូចថាមានសម្តេចអីគាត់មក?

ណាវៈ មកយើងសម្តែងឲ្យគាត់មើលចឹងទៅណាស់ ក្រុមសិល្បៈខ្ញុំហ្នឹងសម្តែងឲ្យមើលទៅជំនាន់ហ្នឹងសម្តេចមក ។

ប៊ុនថនៈ កាលសម្តេចមកនៅឆ្នាំណា?

ណាវៈ កាលមកហ្នឹងមិនដឹងជាឆ្នាំណាទេ កាលហ្នឹងខ្ញុំនៅសិល្បៈ ចេញសិល្បៈហើយដឹងកាលជំនាន់ហ្នឹង ចេញមកនៅដឹកជញ្ជូនហើយ កាលហ្នឹងខ្ញុំចេញពីសិល្បៈហើយខ្ញុំនៅដឹកជញ្ជូន ។

ប៊ុនថនៈ ចឹងនៅពេលគាត់មកមីងមានសម្តែងអីទេ?

ណាវៈ អត់ទេ ។

ប៊ុនថនៈ ចឹងមានក្រុមផ្សេង?

ណាវៈ ចាស! យើងគ្រាន់តែអ្នកឈរទទួល ។

ប៊ុនថនៈ ចឹងកាលគាត់មកមានមនុស្សច្រើនទេ?

ណាវៈ ច្រើនពួកដឹកជញ្ជូនពួកនារីចឹង ចេះតែឈរទទួលទៅ ហើយគេឲ្យហាត់ស្លៀកពាក់ជាទាហានចឹងទៅហាត់ទទួល ។

ប៊ុនថនៈ ចឹងកាលហ្នឹងទាំងសម្តេចតា សម្តេចយាយហ្នឹងមកទាំងអស់?

ណាវៈ ចាស ។

ប៊ុនថនៈ ចឹងថាកូន?

ណាវៈ កូនសម្តេចហ្នឹងក៏មកដែរ ។

ប៊ុនថនៈ ថានៅម៉ាឡៃហ្នឹងអ្នកមីង?

ណាវៈ ចាស! ទូលគ្រាប់ទូអីជាមួយ ។

ប៊ុនថនៈ ជាមួយកងមីងតែម្តង?

ណាវៈ ចាស ។

ប៊ុនថនៈ កូនសម្តេចរាល់ថ្ងៃហ្នឹង?

នារ:		សម្ដេចសីហមុនីហ្នឹងមិនដឹង ខ្ញុំមិនដែរ ដឹងថាមកពីបារាំង សីហមុនីហ្នឹង ។

ប៊ុនថន:	គាត់នៅហ្នឹងដែរ ។

នារ:		ចាស ។

ប៊ុនថន:	នៅពីរនាក់ឬក៏ម្នាក់?

នារ:		កាលហ្នឹងកូនស្ដេចមកពីរ ដល់ពេលថតអ្នកចម្រៀងច្រៀងរាំចឹងទៅ ថតហើយទៅវិញទៅ ដល់យូរបានមកនៅជាប់ មកដំបូងពួកខ្ញុំច្រៀងចឹងទៅ កាលនៅសិល្បៈគាត់មក មកច្រៀងសម្ដែងទៅគាត់ថតជាវីដេអូចឹងទៅណាស់ ។

ប៊ុនថន:	បាទ ។

នារ:		មកយូរបានគាត់មកនៅម្នាក់ទៀត មកជួយដឹកជញ្ជូន មកជួយជញ្ជូនគ្រាប់អីហ្នឹង ។

ប៊ុនថន:	ចឹងទៅនៅជាមួយគ្នាទៅ?

នារ:		គាត់នៅផ្ទះផ្សេងគាត់នៅជាមួយបងថុន បងថុនហ្នឹងឥឡូវគាត់នៅកន្លែងស្ដេចដែរ ។

ប៊ុនថន:	ចឹងនៅរាំង?

នារ:		ចាស!នៅរាំង ។

ប៊ុនថន:	ឈ្មោះអី ថុន?

នារ:		បងថុនហ្នឹងមិនដឹងជាឈ្មោះអីថុនទេ គាត់ទៅនៅកូរេអីឥឡូវ ថានៅស្ថានទូតកូរេ ។

ប៊ុនថន:	ស្ថានទូតកូរេ?

នារ:		ចាស!គាត់ថានៅជាមួយសម្ដេច ។

ប៊ុនថន:	ចឹងកូនសម្ដេចនៅយូរទេ?

នារ:		សម្ដេចនៅយូរដែរ,

ប៊ុនថន:	ចឹងនៅជញ្ជូនគ្រាប់រាល់ថ្ងៃជាមួយមីងទៅ?

នារ:		ចាស!ចេះជញ្ជូនគ្រាប់លីគ្រាប់ដូចតែគ្នា ។

ប៊ុនថន:	ចឹងនៅពេលដែលមីងហៅអីទៅមីងហៅថាម៉េច?

នារ:		អត់ដែលហៅផងសើច... ។

ប៊ុនថន:	ចុះមានអ្នកផ្សេងអីហៅ?

នារ:		មិនដឹងហៅផង ។

ប៊ុនថន:	មានហៅភាសាស្ដេចព្រះអង្គអីទេ?

នារ:		មិនដឹងជាយ៉ាងម៉េចទេ មិនដែលបានហៅផង គ្រាន់តែឃើញៗ ។

ប៊ុនថន:	ចឹងកាលមីងហាត់សិល្បៈហ្នឹងហើយសម្ដែងនៅណាទៅ?

នាវៈ សម្តែងក្នុងស្រុកម៉ាឡៃយើង ។

ប៊ុនថនៈ ដើរសម្តែងឬយ៉ាងម៉េច?

នាវៈ អត់មានដើរអត់ទេ ជំនាន់ហ្នឹងសម្តែងឲ្យតែយោធាមើលចឹងទៅ ។

ប៊ុនថនៈ បាទ ។

នាវៈ សម្តែងនៅពេលភ្ញៀវមក ភ្ញៀវមកចឹងគេចង់មើលទៅ យើងសម្តែងឲ្យគេមើលទៅ ។

ប៊ុនថនៈ មានអ្នកដឹកនាំក្រុមដែរ?

នាវៈ ចាស!មានអ្នកដឹកនាំ ។

ប៊ុនថនៈ ចឹងដឹកនាំក្រុមពីណាវិញ?

នាវៈ តា វិន ។

ប៊ុនថនៈ ចឹង តា វិនហ្នឹងគាត់នៅរស់ដែលសព្វថ្ងៃ?

នាវៈ គាត់នៅរស់ ឥឡូវគាត់ធ្វើជាប្រធានឃុំនៅតា គង់ ។

ប៊ុនថនៈ បាទ ។

នាវៈ ហ្នឹងក្រុមគាត់ជាអ្នកសម្តែង ។

ប៊ុនថនៈ ចឹងគាត់ជាប្រធានសិល្បៈដែលមីង?

នាវៈ ចាស!គាត់ជាប្រធានសិល្បៈ ឈ្មោះ តា វិន ។

ប៊ុនថនៈ ចឹងសិល្បៈហ្នឹងមានស្រីមានប្រុសទេ?

នាវៈ ចាស!មានស្រីមានប្រុសចម្រុះគ្នា ។

ប៊ុនថនៈ ចឹងនិយាយថាដូចជារាល់ថ្ងៃហ្នឹងមីងនៅចេះទេ ដូចថាចេះសម្តែងចេះច្រៀង?

នាវៈ អត់ទេ ឥឡូវចាស់ហើយលែងចេះហើយ ។

ប៊ុនថនៈ ចឹងមីងនៅសិល្បៈហើយបានមកនៅ?

នាវៈ មកនៅដឹកជញ្ជូន ។

ប៊ុនថនៈ ចឹងក្រុមសិល្បៈមានតែរំសាយហើយចឹង?

នាវៈ រំសាយក្រោយមកគេរើសតែក្មេងៗតូចៗ យើងធំគេឲ្យចេញចឹងទៅណាស់ ។

ប៊ុនថនៈ បាទ ។

នាវៈ ចេញយូរៗ ទៅគេរំសាយអស់ទៅ ដល់ពេលយួនវ៉ៃយកស្រុកម៉ាឡៃនេះ ។

ប៊ុនថនៈ បាទ ។

នាវៈ វ៉ៃស្រុកម៉ាឡៃយើងទៅនៅជំរំវៀងខ្នួនគេរំសាយ លែងមានសិល្បៈទៀតហើយបែកគ្នាអស់ទៀតហើយ ។

ប៊ុនថន៖ តែមីងនៅកងដឹកជញ្ជូនដដែល?

នារី៖ ចាស!ខ្ញុំនៅកងដឹកជញ្ជូនដដែល ដល់យួនវ៉ៃទៅនៅដីថៃខ្ញុំមានគ្រួសារទៅ ។

ប៊ុនថន៖ ចឹងមានគ្រួសារនៅណានៅនេះឬនៅណា?

នារី៖ នៅប៉ៃលិន ពេលយួនវ៉ៃនៅនេះយើងទៅដីថៃទៅ កងគ្រួសារខ្ញុំហ្នឹង តា ហុងហ្នឹងគាត់យកទៅនៅប៉ៃលិន ។

ប៊ុនថន៖ ចឹងមីងការតាំងពី?

នារី៖ តាំងពីឆ្នាំ៨៤ ។

ប៊ុនថន៖ ឆ្នាំ៨៤?

នារី៖ ចាស ។

ប៊ុនថន៖ ចឹងមិនទាន់រត់ទៅនោះទេការ?

នារី៖ ការនៅប៉ៃលិន យើងរត់ចេញពីនេះហើយឆ្នាំ៨៣ហ្នឹងយើងរត់ចេញពីនេះ ។

ប៊ុនថន៖ ចឹងកាលឆ្នាំ៨៣ហ្នឹងកំលាំងខាងក្នុងវ៉ៃចូលមក?

នារី៖ ចាស!វ៉ៃចូលដល់នេះយើងចេញ ។

ប៊ុនថន៖ ចឹងមីងចេញទៅណា?

នារី៖ ទៅនៅប៉ៃលិន ។

ប៊ុនថន៖ ទៅនៅប៉ៃលិនឬមួយទៅនៅជំរំ?

នារី៖ ទៅប៉ៃលិន ដល់ចេញពីប៉ៃលិនបានមកនៅជំរំ៨៥ ។

ប៊ុនថន៖ បាទ ។

នារី៖ ទៅនៅប៉ៃលិនមួយរយះ ។

ប៊ុនថន៖ ទៅច្រើនទេមីង?

នារី៖ ទៅទាំងកងចឹងទៅណាស់ ដូចជាកងប្តីខ្ញុំចឹងទៅគាត់ផ្ញើមេកងចឹងទៅ ទៅទាំងអស់គ្នាចឹងទៅទៅជាមួយមេបញ្ជាការចឹងទៅណាស់ ។

ប៊ុនថន៖ បាទ ។

នារី៖ ដល់ពេលទៅនៅនោះបានតែបន្តិចយើងរំសាយទៅនៅជំរំវិញ ជំរំ៨៥ហ្នឹងជាជំរំអ្នកតស៊ូហ្នឹង ។

ប៊ុនថន៖ ចឹងកាលទៅប៉ៃលិនហ្នឹងទៅជាមួយតា ហុង?

នារី៖ ចាស ។

ប៊ុនថន៖ តា ហុងគាត់?

នាវៈ		គាត់ជាមេបញ្ជាការ ។

ប៊ុនថនៈ		ចឹងគាត់ជាមេបញ្ជាការកងពលមីង?

នាវៈ		ចាស ។

ប៊ុនថនៈ		កាលហ្នឹងគេហៅកងពលប៉ុន្មានមីង?

នាវៈ		កងពលប៉ុន្មានទេ ជំនាន់ហ្នឹង កងពលប៉ុន្មានទេ ជំនាន់ហ្នឹងភ្លេចអស់ហើយ ។

ប៊ុនថនៈ		ចឹងមីងទៅការនៅប៉ៃលិនមីង?

នាវៈ		ចាស ។

ប៊ុនថនៈ		កាលហ្នឹងមីងមានស្គាល់គ្នាជាមួយពូទេ?

នាវៈ		ស្គាល់ដែលទៅពីនេះទាំងអស់គ្នា ។

ប៊ុនថនៈ		ចឹងការហ្នឹងគាត់សុំការឬមួយ?

នាវៈ		អង្គការ ការឲ្យ១២គូរ ។

ប៊ុនថនៈ		ចឹងមាននៅសល់រូបថតការទេ?

នាវៈ		អត់មានទេ សើច... ការ១២គូរមានពីណាមាន ។

ប៊ុនថនៈ		ចឹងអត់មានថតទេ?

នាវៈ		មានតើ ។

ប៊ុនថនៈ		មាន?

នាវៈ		នោះ ។

ប៊ុនថនៈ		ចឹងចាំសុំផងមីងសុំទាំងអស់មក?

នាវៈ		ទៅណាអស់ហើយ កាលហ្នឹងមានស្លៀកពាក់ខ្មៅខោអាវគេស្លៀក ។

ប៊ុនថនៈ		ការនៅហ្នឹងតែម្តងមីង?

នាវៈ		ចាស!ការនៅប៉ៃលិន១២គូរ ។

ប៊ុនថនៈ		ចឹងការចឹងដូចថាមានអាចារ្យអីទេ?

នាវៈ		អត់ទេ គេគ្រាន់តែឲ្យយើងមានមតិថាយើងស្រឡាញ់គ្នាចឹងទៅណាស់ យើងស៊ីញ៉ៅទៅ យើងស្រឡាញ់គ្នាទៅ តែប៉ុណ្ណឹង ។

ប៊ុនថនៈ		បាទ! តែមីងមានស្គាល់គាត់ទេពីមុនមក?

នាវៈ		ធ្លាប់នៅជាមួយគ្នាពីនេះទៅ ។

ប៊ុនថនៈ		ធ្លាប់និយាយរកគ្នា?

នាវៈ		អត់ទេ គាត់នៅក្នុងកងអីទេកាលហ្នឹងគាត់ទៅពីនេះទាំងអស់គ្នា ។

ប៊ុនថន: ចឹងអ្នកការផ្សេងទៀតសុទ្ធតែធ្លាប់ស្គាល់គ្នាទាំងអស់ឬយ៉ាងម៉េច?

នាវ: ចាស!ធ្លាប់ស្គាល់គ្នា នៅកងជាមួយគ្នាចឹងទៅ ។

ប៊ុនថន: ធ្លាប់នៅ?

នាវ: ធ្លាប់ជាមួយគ្នាចឹងទៅ ។

ប៊ុនថន: ចឹងនៅជាមួយគ្នាពេញចិត្តគ្នាហើយបានការ?

នាវ: ចាស ។

ប៊ុនថន: ចឹងអត់មានពីណាការហើយអត់ស្រឡាញ់គ្នាទេ?

នាវ: ចាស!គេទៅគេស៊ីញ៉ែទៅ គេមានចាក់មតិគេទៅដូចជាមានមេប្រធានគេមួយគេមានមតិទៅ ។

ប៊ុនថន: បាទ!ចឹងគេឲ្យស៊ីញ៉ែទទួលស្គាល់ដែលមីង?

នាវ: ចាស ។

ប៊ុនថន: ចឹងកាលការឆ្នាំណា?

នាវ: ឆ្នាំ៨៤ ។

ប៊ុនថន: ចឹងការហើយមីងបានមកនៅជំរំនេះតែម្ដង?

នាវ: ចាស!ជំរំ៨៥ ។

ប៊ុនថន: ចឹងការហើយមកនៅទាំងគ្រួសារទាំងអស់?

នាវ: ចាស!ទាំងគ្រួសារទាំងអស់ ។

ប៊ុនថន: ចឹងមីងនៅជំរំ៨៥ហ្នឹង មីងនៅតែចេញចូលមកខ្មែរឬនៅហ្នឹងរហូត?

នាវ: កាលហ្នឹងស្រីៗនៅហ្នឹងប្រុសៗគេចូលមកវៃ ។

ប៊ុនថន: បាទ ។

នាវ: ចូលមកវៃនៅក្នុងនេះទៅយើងនៅក្នុងហ្នឹងទៅ ។

ប៊ុនថន: បាទ ។

នាវ: ដល់គេរំដោះខាងនេះបាន បានគេយកគ្រួសារហ្នឹងមកនៅខាងនេះវិញ ។

ប៊ុនថន: ខាងណាវិញ?

នាវ: ខាងដីយើងវិញ គេដឹកយកមកនៅនេះវិញឆ្នាំ៩៣ ។

ប៊ុនថន: ឆ្នាំ៩៣?

នាវ: ចាស!៩៣ហ្នឹងជំនាន់អ៊ុនតាក់ហើយកាលហ្នឹង ។

ប៊ុនថន: បាទ ។

នាវៈ យើងត្រូវគ្នាហើយ ។

ប៊ុនថន: ចឹងមីងនៅហ្នឹងមីងមិនឡើងមកមីងធ្វើអីវិញ?

នាវៈ ចុះយើងមានគ្រួសារមានកូនគេឲ្យនៅផ្ទះ ហើយប្តីៗគេឲ្យមកវៃចឹងទៅណាស់ ៥ ទៅ៦ ខែ ទៅម្តងចឹងទៅ ។

ប៊ុនថន: ទៅម្តង?

នាវៈ ចាស!ដល់គេរំដោះព្រំដែនហើយបានគេដឹកប្រជាជនមក មកព្រំដែនវិញ ។

ប៊ុនថន: ចឹងនិយាយថាមីងនៅហ្នឹងអត់មានធ្វើអីទេ?

នាវៈ ចាស ។

ប៊ុនថន: ចុះរបបហូប?

នាវៈ របបហូបចុករដ្ឋគេបើកឲ្យ មួយអាទិត្យបើកម្តងមានអង្ករស្ករប៊ីចេងអំបិលប្រហុកអីចឹងទៅណាស់គ្រប់មុនទៅ ។

ប៊ុនថន: បាទ!ចឹងមីងមានកូនហើយនៅកាលហ្នឹង?

នាវៈ មានមួយហើយ នោះមួយស្រី ។

ប៊ុនថន: មីងកើតឆ្នាំណា?

នាវៈ កើតកាលឆ្នាំ៨៧ ការ៨៤ ។

ប៊ុនថន: ចឹងមីងនៅហ្នឹងនៅកងដឹកជញ្ជូនដដែល?

នាវៈ អត់ទេ យើងមានប្តីហើយគេឈប់ឲ្យនៅកងដឹកជញ្ជូនហើយ គេឲ្យធ្វើផ្ទះមួយនៅដោយឡែកពីគ្នាចឹង ។

ប៊ុនថន: បាទ ។

នាវៈ ផ្ទះប្រក់កៅស៊ូចឹងទៅ ផ្ទះដោយឡែកៗយើងមានគ្រួសារហើយយើងនៅដឹកជញ្ជូនផ្ទះនៅរួមគ្នា ។

ប៊ុនថន: ចឹងនៅហ្នឹងចេញពីកងដឹកជញ្ជូនហើយ?

នាវៈ ចាស!ឲ្យតែយើងមានគ្រួសារគេឲ្យចេញពីកងហើយ ។

ប៊ុនថន: ចឹង៩៣បានមីងជាមួយគ្រួសារមីងមកនៅនេះជាមួយគ្នា?

នាវៈ ចាស!៩៤ ជំនាន់អ៊ុនតាក់នោះ ។

ប៊ុនថន: ៩០ប៉ុន្មាន?

នាវៈ មកនៅនេះឆ្នាំ៨៩ហើយ ។

ប៊ុនថន: ចឹង៨៩?

នាវៈ ចាស!កាល៨៩ហ្នឹងយើងត្រូវគ្នាតិចៗហើយ ។

ប៊ុនថន: ចឹង៨៩មីងមកនៅណា?

នាវៈ មកនៅមាត់អូរហ្នឹង កាលមកដល់ដំបូងសុទ្ធមីន យើងនៅមាត់អូរដល់ហើយបានមកទិញដីគេមកនៅនេះ ។

ប៊ុនថន: ចឹងដីនេះមិនមែនចាប់បានទេ?

នាវៈ អត់ទេ ប្តីនៅមុខមិនដែលមានដីចាប់ទេ ទិញទាំងអស់ ។

ប៊ុនថន: បាទ ។

នាវៈ គេអត់ទៅមុខគេយកបានទៅ ។

ប៊ុនថន: ចឹងនៅមាត់អូរនេះគេចែកឲ្យតើ?

នាវៈ អត់ទេ មកនៅដូចជាដីគេរាវមីនហើយបានបន្តិចហើយយើងចេះតែមកធ្វើខ្ទមនៅតិចៗទៅជិតៗគ្នាចឹងទៅ ។

ប៊ុនថន: បាទ ។

នាវៈ ដល់ពេលអស់មីនទៅ គេឈូសអីអស់ទៅចែកដីគ្នាអស់ទៅ ខ្ញុំមកទិញដីគេនៅនេះវិញ ។

ប៊ុនថន: ថ្លៃប៉ុន្មានដីនៅជាប់ផ្លូវផង?

នាវៈ កាលទិញដំបូងដីតូចដែលហ្នឹង ជំនាន់ហ្នឹងប៉ុន្មានពាន់ហ្នឹង ៦ទៅ៧ពាន់ ។

ប៊ុនថន: ៦ទៅ៧ពាន់បាត?

នាវៈ ចាស ។

ប៊ុនថន: ចឹងមានបានដីចំការអីទៀតទេ?

នាវៈ ដីចំការអត់ទេ សុទ្ធតែទិញទាំងអស់ អត់មានបានចាប់ទេខ្លាចមីន ម្យ៉ាងយើងនៅតែពីរនាក់កូនយើងមិនហ៊ានទៅចាប់ដីនៅខាងមុខ ។

ប៊ុនថន: បាទ ។

នាវៈ យើងនៅតែពីរនាក់កូន ។

ប៊ុនថន: កូនប៉ុន្មាននាក់មីង?

នាវៈ កូនបីនាក់ ។

ប៊ុនថន: ស្រីបងគេ?

នាវៈ ចាស ។

ប៊ុនថន: ក្រោយៗប្រុសៗ?

នាវៈ ចាស ។

ប៊ុនថន៖ ដីចំការមានបានច្រើនទេ?

នាវៈ ទេ បានបន្តិចបន្តួចដែរ យើងទិញអត់មានចាប់បានហ្នឹងគេផង ។

ប៊ុនថន៖ ចុះមីងមក៩៣ហ្នឹងមកនេះមានព្រៃទេ មីង?

នាវៈ ព្រៃទាំងអស់អត់មានវាលចេះទេ ព្រៃឡើងស្ដុកស្ដម្ភសុទ្ធតែព្រៃឫស្សីដើមបេងដើមស្រឡៅ ដើមស្អីមើលគ្មានមិនឃើញទេ សុទ្ធតែព្រៃ ។

ប៊ុនថន៖ ចឹង៩៣ហ្នឹងនៅព្រៃទេ មីង?

នាវៈ ចាស!ព្រៃទាំងអស់ អត់មាន មានវាលចេះទេ ។

ប៊ុនថន៖ ចុះផ្លូវមុខអីមានទេ?

នាវៈ ផ្លូវនេះយើងដើរដីធម្មតាចឹងទៅ ផ្លូវអស់នេះយើងចេះតែដើរៗជំនាន់៩៣ដែលថៃមកទិញឈើអីហ្នឹង គេធ្វើផ្លូវហ្នឹងឲ្យ គេឈូសហើយគេលើកជាផ្លូវ ។

ប៊ុនថន៖ ចឹងដំបូងជាផ្លូវថ្មីដើង?

នាវៈ ដីយើងដើរធម្មតា ផុងត្រឹមនេះចឹងទៅ ។

ប៊ុនថន៖ ទើបតែថៃធ្វើឲ្យ?

នាវៈ ចាស!គេទិញឈើចឹងទៅគេធ្វើឲ្យយើងចឹងទៅ ។

ប៊ុនថន៖ ចឹងដីហ្នឹងថៃឈប់ឈូសដល់ណាទៅ?

នាវៈ ចេះតែទៅៗទៅដល់ខ្វាងវាប់ទៅ ។

ប៊ុនថន៖ ខ្វាងវាប់ហ្នឹងមីង ហ្នឹងសុទ្ធតែដីថៃឈូសទៅទិញឈើ?

នាវៈ ធ្វើផ្លូវឲ្យយើងណាស់ ដឹកឈើ ។

ប៊ុនថន៖ ចឹងគេធ្វើឲ្យយើង ដើម្បីដឹកឈើអីហ្នឹងមីង?

នាវៈ ចាស!យើងអត់មានឧបករណ៍ទេ ។

ប៊ុនថន៖ ចឹងបានកកើតផ្លូវរាល់ថ្ងៃ?

នាវៈ ចាស!ដល់រាល់ថ្ងៃកាលជំនាន់មុន ដើរតែដីទទេហ្នឹងផុង អត់មានផ្លូវឡានបើកទេ ។

ប៊ុនថន៖ តែជុំវិញមួយជួរហ្នឹងសុទ្ធតែព្រៃ?

នាវៈ ចាស!សុទ្ធតែព្រៃតែប្រជាជននៅយូរៗ ឆ្កាវាលទៅ ។

ប៊ុនថន៖ ចឹងកាល៩៣ហ្នឹងមានមីននិងប្រជាជនរស់នៅយ៉ាងម៉េចដែរមីង?

នាវៈ នៅម្តុំនេះមិនមានមីនទេ មានតាមមាត់អូរ មាត់អូរមានមីនផ្ទុះសឹករាល់ថ្ងៃ នៅម្តុំនេះខ្សែមីនចឹងទៅណាស់ តែមានអ្នកខ្លះចេះដោះខ្លួនគេ ។

ប៊ុនថន៖ ចឹងគ្រាប់មីនដំបូងមានចាប់តាំងពីឆ្នាំណាមីង?

| | |
|---|---|
| នាវៈ | មីនអស់នេះដូចខាងក្រុមទាហានខាងក្នុងគេដាក់ គេដាក់ជារបងហើយគេដាក់ជាមីនរហូត មីនឆ្នាំ៨៤យួនដាក់ គេវៃមកគេមិនដាក់មីនយើងរត់ទៅដីថៃទៅ ។ |
| ប៊ុនថន: | កាលមីងមកដំបូងមិនទាន់មានទេ? |
| នាវៈ | អត់ទេ មកដំបូងមិនមានមីនសោះ ឆ្នាំ៨០បានមានមីន នៅពេលគេវៃបានដីនេះទៅយើង មិនរត់ទៅដីថៃអស់ បានគេដាក់មីន ដល់យើងចូលមកវិញសុទ្ធមីន ។ |
| ប៊ុនថន: | ចឹងមានអ្នកគ្រោះថ្នាក់មានអីទេ? |
| នាវៈ | មានច្រើន មានដាច់ជើងទាំងពីរ ដាច់ជើងសឹកគ្រប់តែគ្នា ។ |
| ប៊ុនថន: | ចឹងដោយសារយើងជាន់មីន? |
| នាវៈ | ដោយសារយើងជាន់មីន កាប់ចំការនិងយើងឆ្កាដីនៅហ្នឹងជាន់មីនដាច់ជើងទាំងពីរហ្នឹង មានស្លាប់ខ្លះ ខ្លះដាច់ជើងសឹងរាល់តែថ្ងៃ ។ |
| ប៊ុនថន: | បាទ ។ |
| នាវៈ | ចឹងខ្មែរមីនគេដាក់ហើយ គេដាក់យើងអ្នកដើរ ។ |
| ប៊ុនថន: | ចឹងដូចថាដីអីយើងចាប់បានយកប៉ុណ្ណឹងតែម្តងមីង? |
| នាវៈ | គេចាប់បានប៉ុន្មានគេយកប៉ុណ្ណឹងទៅ តែខ្ញុំមិនមានដីចាប់ប្តីនៅសមរភូមិ យើងមានកូនតូច ចឹងយើងមិនហ៊ានដើរ សុទ្ធតែគ្រាប់ខាចមីន ។ |
| ប៊ុនថន: | ចឹងកាលមកនៅឆ្នាំ៩៣នៅមានរបបបើកទេមីង? |
| នាវៈ | ចាស!នៅមានរបបបើកអង្ករបើករាល់ខែ មួយខែម្តងៗប្តីយើងនៅវៃ ទើបតែដាច់របប ជំនាន់យើងហ្នឹង ជំនាន់៩៧/ជំនាន់យើងផ្តាច់ខ្លួនហ្នឹង ។ |
| ប៊ុនថន: | ហ្នឹងអត់មានរបបទេ ក្រោយមកហ្នឹង? |
| នាវៈ | អត់មានទេ កាលមុនហ្នឹងមានរបបរហូតយើងនៅវៃគ្នាហ្នឹង ប្តីនៅមុខយើងនៅក្រោយគេ បើអង្ករ ។ |
| ប៊ុនថន: | ចឹងគ្រួសារអ្នកមីងធ្វើជាទាហានរហូតដល់ឆ្នាំណា? |
| នាវៈ | ទើបឈប់ប៉ុន្មានឆ្នាំនេះ ។ |
| ប៊ុនថន: | ចឹងគាត់ឥឡូវទៅសៀមរាបមីង? |
| នាវៈ | ចាស ។ |
| ប៊ុនថន: | គាត់ធ្វើការអីដែលមីង? |
| នាវៈ | គាត់មានធ្វើអីទេ ។ |
| ប៊ុនថន: | រកស៊ីប៉ុមួយធ្វើអីវិញ? |

នាវៈ	ចាស!រកស៊ី ។

ប៊ុនថនៈ	យូរៗមកម្ដង?

នាវៈ	ចាស ។

ប៊ុនថនៈ	ចឹងកាលមីងមកដំបូងកាលហ្នឹងហៅម៉ាឡៃឬមិនទាន់មានឈ្មោះម៉ាឡៃទេ?

នាវៈ	ជំនាន់ហ្នឹងគេហៅតំបន់៥០២ ។

ប៊ុនថនៈ	មិនទាន់មានឈ្មោះម៉ាឡៃទេ?

នាវៈ	មាន គេហៅភ្នំម៉ាឡៃនេះ តែគេហៅតំបន់៥០២ ដូចថាតំបន់នេះតំបន់នោះចឹងទៅណាស់ ។

ប៊ុនថនៈ	ចឹងតំបន់នេះគេហៅ៥០២តែម៉ាឡៃគេមានហៅហើយឬនៅ?

នាវៈ	ជំនាន់ហ្នឹងភ្នំម៉ាឡៃនេះវាមានយូរហើយ តែជំនាន់ឆ្នាំ៨០គេដាក់ឈ្មោះតំបន់អីគេទេ កាលហ្នឹងគេមានលេខគេដូចជាសំពៅលូនគេមានលេខគេផ្សេងទៅ ប៉ៃលិនមានលេខផ្សេងចឹងទៅ ជំនាន់ហ្នឹងស្រុកម៉ាឡៃគេហៅស្រុកអីទេ ភ្លេចអស់ហើយជំនាន់ហ្នឹង ។

ប៊ុនថនៈ	ចឹងម៉ាឡៃហ្នឹងឈ្មោះដំបូងយ៉ាងម៉េចបានគេហៅឈ្មោះម៉ាឡៃហ្នឹង?

នាវៈ	ចុះមានភ្នំម៉ាឡៃយើងនេះ ។

ប៊ុនថនៈ	ចឹងយ៉ាងម៉េចបានគេហៅភ្នំម៉ាឡៃ?

នាវៈ	ភ្នំម៉ាឡៃមានឈ្មោះតាំងពីសង្គមមក ។

ប៊ុនថនៈ	ចឹងមានជាប់មកដល់ឥឡូវ?

នាវៈ	ចាស!មានជាប់មកដល់ឥឡូវ ។

ប៊ុនថនៈ	ចឹងដូចជាឈ្មោះភូមិឃុំអីហ្នឹង មានតាំងពីឆ្នាំ៨០ហ្នឹង?

នាវៈ	ទេ ទើបតែដាក់ឥឡូវតើ ទើបដាក់យើងផ្ដាច់ខ្លួនហ្នឹងមានឈ្មោះភូមិនេះភូមិនោះចឹង ។

ប៊ុនថនៈ	កើតចេញជាស្រុកមួយទៅ?

នាវៈ	ចាស!កាលជំនាន់មុនយើងមិនសូវមានប្រជាជនណា ជំនាន់មុនវ៉ៃគ្នាប្រជាជនតិច ។

ប៊ុនថនៈ	បាទ ។

នាវៈ	កាលហ្នឹងមិនមានកើតជាភូមិជាស្រុកទេ យើងនៅកងនេះកងនោះជំនាន់វ៉ៃគ្នា យើងនៅកងវរៈនេះកងវរៈនោះចឹង ។

ប៊ុនថនៈ	បាទ ។

នាវៈ	ដល់យើងផ្ដាច់ខ្លួនហើយបានយើងមានភូមិឃុំស្រុក កាលជំនាន់ហ្នឹងយើងមិនមានទេ ។

ប៊ុនថន៖ មីងចង់សួរត្រឡប់ទៅក្រោយបន្តិចណាស់ កាលមីងនៅរៀនហ្នឹងមីងបែកចេញពីផ្ទះនៅឆ្នាំណាមីង?

នាវ៖ ខ្ញុំបែកចេញតាំងពី៧៥តែម្តង ។

ប៊ុនថន៖ ៧៥?

នាវ៖ មកនៅជីកទំនប់លើកទំនប់ប្រឡាយអីតាមគេតាមឯងចឹងមក ។

ប៊ុនថន៖ ចឹងកាលឈប់រៀនហើយហ្នឹងមីងនៅកង?

នាវ៖ ចាស!ឈប់រៀនហើយហ្នឹងឆ្នាំ៧៥ហ្នឹងគេរៀនដែលតែគេរៀននៅព្រៃ ។

ប៊ុនថន៖ បាទ ។

នាវ៖ រៀនតិចៗចឹងទៅ ដល់យើងផ្លាស់ទៅណាទៅណីឈប់រៀនទៅ ខ្ញុំរៀនបានតែបន្តិច ។

ប៊ុនថន៖ ចឹងតាំងពីមុន៧៥ហ្នឹងមីងនៅរៀនទេ?

នាវ៖ រៀនបន្តិចៗ ។

ប៊ុនថន៖ ចឹងកាលហ្នឹងនៅខាងណា?

នាវ៖ នៅខាងតំបន់ខ្មែរក្រហម ។

ប៊ុនថន៖ នៅខាងកំលាំងតស៊ូឬមួយនៅខាងកំលាំងលន់ នល់?

នាវ៖ នៅតំបន់តស៊ូ កាលជំនាន់ហ្នឹងគេវ៉ៃតែទីក្រុងតើ យើងនៅហ្នឹងជាតំបន់តស៊ូហើយ ។

ប៊ុនថន៖ បាទ ។

នាវ៖ យន្តហោះទម្លាក់ហ្នឹងយើងរត់ចូលព្រៃណាស់ ។

ប៊ុនថន៖ រត់ចូលព្រៃយើងរត់ចូលព្រៃទៅ?

នាវ៖ ចាស! រៀននៅព្រៃក្រោមដើមឈើធំៗចឹងទៅ យើងធ្វើប្រក់ស្បៀវក្រោមដើមឫស្សី ។

ប៊ុនថន៖ ចឹងទៅទាំងអស់មីងទៅទាំងឪពុកម្តាយ?

នាវ៖ អត់ទេ ចាស់ៗជំនាន់ហ្នឹងគេឲ្យរៀនអក្ខរកម្មចឹងទៅ ។

ប៊ុនថន៖ ចឹងកាលរត់ទៅក្នុងព្រៃទាំងម្តាយមីង?

នាវ៖ អត់ទេ នៅក្នុងព្រៃហ្នឹងនៅផ្ទះយើងស្រាប់ទេ តែយើងរៀននៅសាលាក្នុងព្រៃណាស់ ។

ប៊ុនថន៖ បាទ ។

នាវ៖ រៀនក្នុងព្រៃខ្លាចយន្តហោះទម្លាក់អីចឹងទៅណាស់ ។

ប៊ុនថន៖ បាទ ។

នាវ៖ កាលហ្នឹងអាយុតិចចឹងយើងកើតមិនទាន់គេរៀនពីសង្គម ។

ប៊ុនថន៖ ចឹងបងមីងអីនៅរៀនដែរ?

នារី៖ នៅរៀន ដល់ពេលជំនាន់ហ្នឹងគេឈប់រៀនមានសាលារៀនណា ខ្ញុំដឹងត្តិមកមិនដែលឃើញគេរៀនផង ។

ប៊ុនថន៖ បាទ ។

នារី៖ រៀនជំនាន់ហ្នឹងគេវ៉ៃគ្នាហើយ ឆ្នាំ៧២គេឈប់រៀនហើយ ។

ប៊ុនថន៖ ចឹងមីងនៅរៀនរហូតដល់?

នារី៖ រៀនបានបន្តិចៗហ្នឹង រៀនបានមួយខែពីរខែឈប់រៀន ជំនាន់ហ្នឹងរៀនបានតិចៗក្នុងព្រៃរៀនបានមួយភ្លែតៗ ។

ប៊ុនថន៖ បាទ!ចឹងកាលឆ្នាំ៧៥មីង?

នារី៖ ឆ្នាំ៧៥ខ្ញុំចេញពីផ្ទះ ទៅលើកទំនប់ជីកប្រឡាយហើយស្ទូងដក ខែប្រាំងលើកភ្លឺស្រែចឹងទៅជីកទំនប់លើកប្រឡាយចឹងទៅ ។

ប៊ុនថន៖ តែនៅក្នុងឃុំដដែរ?

នារី៖ ទេ នៅក្នុងឃុំដដែល ដល់ស្ទូងឃុំគេហៅចឹងទៅយើងស្ទូងឃុំហើយយើងទៅជួយស្ទូងឃុំគេទៀតទៅ យើងស្ទូងឃុំគេហើយយើងទៅក្រោមទៅទន្លេធ្វើស្រែប្រាំងទៀតទៅណាស់ ។

ប៊ុនថន៖ បាទ!គេហៅក្រុមបង្កាស់ដៃ?

នារី៖ អត់ទេ កងហ្នឹងគេទៅធ្វើចឹងតែម្តង ។

ប៊ុនថន៖ កងចល័ត?

នារី៖ ចល័តតែគ្រាន់ខ្ញុំកងកុមារ ។

ប៊ុនថន៖ កាលហ្នឹងមីងអាយុប៉ុន្មានហើយមីង?

នារី៖ អាយុ១៣ ។

ប៊ុនថន៖ នៅក្មេងដែរ?

នារី៖ ចាស!កាប់ដំបូកទម្លាយដំបូកដាក់ស្រែចឹងទៅ ចុះជំនាន់ហ្នឹងខ្វះអីគេប្រើយើង ។

ប៊ុនថន៖ សម្បូរការងារ?

នារី៖ ចាស!គេមិនឲ្យយើងទំនេរខែប្រាំងគេឲ្យយើងទំនប់ប្រឡាយចឹងទៅ ដល់ជីកហើយអស់ខែវស្សាគេឲ្យយើងដកស្ទូងចឹងទៅ ។

ប៊ុនថន៖ បាទ ។

នារី៖ ស្ទូងហើយអស់ខែប្រាំងអត់លើកទំនប់ជីកប្រឡាយគេឲ្យយើងកាប់ដំបូកដាក់ស្រែចឹងទៅ ។

ប៊ុនថន៖ ចឹងមីងនៅកងចល័តរហូតឬមួយផ្លាស់មកខាងណាវិញមីង?

នាវៈ ដល់ខ្ញុំនៅហ្នឹងដល់ឆ្នាំ៧៨ ខ្ញុំឡើងមកកំពង់សោមយកកុមារមកនៅកំពង់សោម យកមកភូមិភាគកាលហ្នឹង ។

ប៊ុនថនៈ ភូមិភាគ?

នាវៈ ចាស!កាលពីមុននៅកងកុមារស្រុក ។

ប៊ុនថនៈ គេហៅស្រុកអីវិញមីង?

នាវៈ ស្រុកអង្គរជ័យក្រោយមកគេយកមកនៅភាគ យកមកនៅកំពង់សោម ។

ប៊ុនថនៈ ចឹងមកនៅកំពង់សោមវិញ?

នាវៈ ចាស!មកនៅធ្វើដូងអីហ្នឹងនៅចំការដូង ។

ប៊ុនថនៈ នៅចំការដូង?

នាវៈ ចាស ។

ប៊ុនថនៈ តែហ្នឹងគេហៅអីវិញ ភូមិភាគ?

នាវៈ កាលហ្នឹងយើងនៅភាគមិនឡើងមជ្ឈិមទេ បើមជ្ឈិមគេនៅភ្នំពេញណាស់ ។

ប៊ុនថនៈ បាទ!កាលហ្នឹងភូមិភាគអីវិញ?

នាវៈ ភូមិភាគនិរតី នៅកន្លែងចំការដូងមានកុមារ៣០០យកមកចឹងណាស់ ។

ប៊ុនថនៈ បាទ ។

នាវៈ គេដឹកមកឲ្យមករើសផ្លែដូងយកទៅធ្វើសាប៊ូអីចឹងទៅ ។

ប៊ុនថនៈ ចឹងក្រៅពីដូងហ្នឹងមានធ្វើការអីទៀតមីង?

នាវៈ អត់ កាប់ឆ្កាព្រៃដូងរើសដូង យើងរើសគមួយដុំៗទៅយើងឆ្កាព្រៃឲ្យវាលទៅ ។

ប៊ុនថនៈ ចឹង៣០០នាក់ហ្នឹងស្រីទាំងអស់ឬមានប្រុសដែរ?

នាវៈ ស្រីៗទាំងអស់ ។

ប៊ុនថនៈ ចឹងមានមេកងគេទេ?

នាវៈ មានមេកងគេក្រមុំៗចឹងទៅ ដល់ពេលហ្នឹងយួនវៃមកយើងចេះតែរត់មកទៅ រត់តាមគេតាមឯងមក ។

ប៊ុនថនៈ កាលរត់ដំបូងរត់ទៅខាងណាវិញមីង?

នាវៈ រត់ទៅសាក់ស្តានៅថ្មបាំង ។

ប៊ុនថនៈ ថ្មបាំងហ្នឹងនៅកោះកុងមីង?

នាវៈ ចាស!នៅថ្មបាំងទៅចូលមកខ្នងយៃ ឡើងភ្នំរាប់ខែបានចុះមកនៅខ្នងយៃ ។

ប៊ុនថនៈ បាទ ។

នាវៈ	នៅខ្ទង់ប៉ៃ ហើយបានគេថាទៅស្រុកម៉ែយើង ជួបពុកម៉ែយើងវិញបានយើងមក កាលហ្នឹងមានជំរំដែរ ថៃវាដឹកយកមកដាក់ត្រាង ។

ប៊ុនថន:	បាទ ។

នាវៈ	ត្រាងយើងហ្នឹងចេះតែនៅជំនាវៗ ព្រំដែនរហូតចឹងទៅណាស់ ចេះតែនៅជំនាវៗ ព្រំដែនចឹងទៅ ។

ប៊ុនថន:	បានចូលមកដល់នេះ?

នាវៈ	ចូលមកដល់នេះចឹងទៅបានយួនវ៉ៃមួយសារទៀត យើងទៅនៅស្រះកែវធ្លាក់មកនៅដីថៃទៀត ។

ប៊ុនថន:	ចឹងមីងមកហ្នឹងមកតាមគ្នាឬមួយមានអ្នកនាំមក?

នាវៈ	ដំបូងមានអ្នកដឹកនាំដល់យូរទៅអត់មានអន្តរអីហូប ខ្លះបែកគ្នាស្លាប់អីអស់ទៅ នៅតែពីរបីនាក់ចេះតែដើរៗ មកហ្នឹងគេទៅ ។

ប៊ុនថន:	ចឹងកាលមកដំបូងច្រើនទេមីង?

នាវៈ	គ្នា៣០០នាក់ទៅ៤០០ ។

ប៊ុនថន:	បាទ ។

នាវៈ	ដល់រត់បែកគ្នាខ្លះស្លាប់ទៅខ្លះដាច់បាយអីចឹងទៅឡើងភ្នំនោះ ។

ប៊ុនថន:	ស្លាប់ដោយសារអីវិញមីង?

នាវៈ	អត់បាយ នៅពេលឡើងភ្នំដល់ចឹងស្លាប់បាត់អស់ ខ្លះណាក៏ត្រូវគ្រាប់ស្លាប់ចឹងទៅចុះផ្លោងមកខ្ទង់ៗ នោះ ។

ប៊ុនថន:	បាទ ។

នាវៈ	រត់មកឡើងភ្នំមកដល់ហើយ យើងឆ្លងមកដីខ្មែរទៅហើយចូលទៅខាងវាលវែងយើងពោធិសាត់ហ្នឹង ។

ប៊ុនថន:	បាទ ។

នាវៈ	គ្រាន់តែរកឆ្លងស្ទឹងមកដីខ្មែរវិញយួនផ្លោងខ្ទង់ៗ ក៏រត់បែកគ្នាចូលព្រៃ ។

ប៊ុនថន:	បាទ ។

នាវៈ	ចូលព្រៃហើយចេះតែមកចឹងទៅ ខ្លះអត់បាយស្លាប់ចឹងទៅដល់ហើយបែកគ្នាអស់កុមារហ្នឹង ។

ប៊ុនថន:	បាទ ។

នាវៈ ទៅជាឯកជននរណាអត់បាយក៏ស្លាប់ទៅ ណាមានបាយរស់ទៅមានអង្ករមួយក្តាប់ពីរក្តាប់ក៏ចេះតែបបរហូបទៅតមកបានមកធ្លាក់ដីថៃ ។

ប៊ុនថន: បាទ ។

នាវៈ ខ្ញុំទាហានគេឲ្យអង្ករ ទាហានគេឡើងវៃគេយកមិនរួចគេថាអូនយកអង្ករគេឲ្យថ្នក់មកយើងដាក់ក្នុងស្បោងមួយចេះតែបបរហូបទៅម្តងមួយក្តាប់ទៅហើយបានមកដល់ដីថៃពីរនាក់នៅភូមិជាមួយគ្នាហ្នឹង ។

ប៊ុនថន: ចឹងនៅតែពីរនាក់មីងទេបែកគ្នាអស់?

នាវៈ ចាស!៥នាក់ឡើងពីស្រុកមកតែស្លាប់អស់ហើយបាត់ខ្លួន ក្រោយមកគេថាងាប់មិនងាប់ដោយសារអី ។

ប៊ុនថន: បាទ ។

នាវៈ នៅតែពីរនាក់យើងរត់តាមគេហ្នឹងមកយើងចូលដីថៃ ។

ប៊ុនថន: ចឹងតែពីរនាក់មិត្តភក្តិតែមានអ្នកផ្សេងទៀត?

នាវៈ ចាស!មានអ្នកផ្សេងនៅចេះស្គាល់មីងៗគេចេះតែនាំយើងទៅណាស់ គេចាស់យើងក្មេង ។

ប៊ុនថន: ចឹងកាលហ្នឹងអត់មានរត់ទៅក្រោយវិញទេ?

នាវៈ អត់ទេ ។

ប៊ុនថន: យ៉ាងម៉េចបានមីងមិនរត់ទៅ?

នាវៈ ខ្លាចចេះតែថាយួនដេញៗចឹងទៅចេះតែរត់ទៅ ។

ប៊ុនថន: បាទ ។

នាវៈ រត់តាមគេតាមឯងទៅធ្លាក់ដីថៃ ដល់ហើយគេថាទៅស្រុកជួបជុំម៉ែយើងថៃក៏ដឹកមកដីខ្មែរវិញមក ។

ប៊ុនថន: បាទ ។

នាវៈ ដឹកមកដីខ្មែរគេវៃមកទៀតយើងរត់ទៅថៃទៀត ថៃទៀតគេដឹកយកទៅដាក់ជំរំស្រះកែវដល់ហើយគេថាយើងទៅខ្មែរជួបជុំម៉ែឪយើងវិញ មកដីខ្មែរទៀតមក ។

ប៊ុនថន: បាទ ។

នាវៈ កាលហ្នឹងមានគេទៅក្រៅយើងមិនទៅទេ កាលហ្នឹង ។

ប៊ុនថន: បាទ ។

នាវៈ កាលហ្នឹងកុមារគេដឹកដល់អាមេរិចអីនោះ ខ្ញុំមកដីខ្មែរយើងនេះវិញ ក្រយោយើងនៅតែខ្មែរ ។

ប៊ុនថន: ចឹងមានអ្នកខ្លះទៅស្រុកគេចឹងទៅ?

នារ៉: ចាស!អ្នកនៅជាមួយខ្ញុំខ្លះគេទៅស្រុកគេអស់ហើយ ។

ប៊ុនថន: ចឹងអ្នកដែលធ្លាប់ទៅមានធ្លាប់មកលេងទេមីង?

នារ៉: គេមកតើ គេចូលជិរំគេមិនចេញណាស់ គេនៅជិរំហ្នឹងគេដឹកទៅស្រុកគេហើយ យើងចេះតែមករកម៉ែឪយើង ។

ប៊ុនថន: បាទ ។

នារ៉: យើងចេះតែមកខ្មែរវិញ ។

ប៊ុនថន: ចឹងមួយកងមីងហ្នឹងរត់បែកគ្នាឬមួយស្លាប់មីង?

នារ៉: រត់បែកគ្នាអស់ទៅ ខ្លះអត់បាយអត់ទឹកស្លាប់ចឹងទៅ រត់ឡើងភ្នំចឹងទៅ ។

ប៊ុនថន: នៅសល់ប៉ុន្មាននាក់មីង?

នារ៉: អត់មានឃើញមិនដឹងទៅណាទៅណីអស់ទៅ ខ្ញុំរត់មកតែគ្នាបីបួននាក់ ។

ប៊ុនថន: បាទ ។

នារ៉: ចុះជំនាន់ហ្នឹងនៅពេលយើងអត់មានពីណាជួយណា ។

ប៊ុនថន: ចឹងមីងបែកពីផ្ទះតែម្តងនៅឆ្នាំណា?

នារ៉: ៧៥ហ្នឹងយើងនៅកងកុមារក្នុងស្រុក ។

ប៊ុនថន: តែមិនដែលចូលជួបឪពុកម្តាយទេ?

នារ៉: ចូលពេលណាយើងនឹកយើងទៅៗ ចុះនៅក្នុងឃុំដល់យើងចេញពីផ្ទះដាច់នៅឆ្នាំ៧៨ ។

ប៊ុនថន: ចឹង៧៨ហ្នឹងមីងដែលងបានជួបគាត់ហើយ?

នារ៉: ចាស!លែងបានជួបហើយហ្នឹងយើងទៅនៅកំពង់សោមហើយ ។

ប៊ុនថន: ចឹងបងៗមីងមានបានចេញទៅតស៊ូដែរ?

នារ៉: បងៗខ្ញុំចេញទាំងអស់ ។

ប៊ុនថន: ចេញទាំងអស់?

នារ៉: ចាស!នៅតែពីរនាក់ប្អូនតូច ចេញស្លាប់អស់ ។

ប៊ុនថន: គាត់ចេញទៅខាងទ័ពមីង?

នារ៉: ចាស ។

ប៊ុនថន: គាត់ចេញមុនមីងឬក្រោយមីង?

នារ៉: ចេញមុន ។

ប៊ុនថន: ចឹងពីរនាក់ហ្នឹងមុនមីង?

នាវៈ ចាស ។

ប៊ុនថនៈ ចឹងនៅពេលចេញឆ្នាំ៧៨បែកពីផ្ទះហ្នឹងមានដែលទទួលដំណឹងពីគាត់ទេមីង?

នាវៈ អត់ទេ ដល់ពេលហើយស្លាប់មួយ នៅឆ្នាំ៧៦ស្លាប់នៅកំពង់សោមម្នាក់ ។

ប៊ុនថនៈ បាទ ។

នាវៈ ដល់ពេលឆ្នាំ៨៣នេះស្លាប់នៅកោះកុងម្នាក់ទៀត ។

ប៊ុនថនៈ គាត់ស្លាប់ដោយសារអីដែលមីង?

នាវៈ គាត់ត្រូវរបួស គាត់ត្រូវរបួសជើងចឹងទៅយើងនៅក្នុងព្រៃយើងនៅខ្មែរក្រហមចឹងទៅដល់អត់មានថ្នាំព្យាបាលចឹងទៅ សើរើរបួសស្លាប់ទៅ ។

ប៊ុនថនៈ ចឹងផ្សេងទៀតនៅរស់ទាំងអស់មីង?

នាវៈ នៅរស់បីនាក់តូចៗ បងនោះទៅធ្វើទាហាននៅពេលយួនមកគេទៅនៅផ្ទះវិញទៅណាស់ ។

ប៊ុនថនៈ បាទ ។

នាវៈ បីនាក់ទៀតនៅតូចៗ នៅជាមួយម៉ែ ។

ប៊ុនថនៈ ចឹងសព្វថ្ងៃបងប្អូននៅរស់ប៉ុន្មាននាក់?

នាវៈ នៅបួននាក់ ។

ប៊ុនថនៈ ចឹងស្លាប់បីនាក់?

នាវៈ ចាស! ពេលរត់ទៅស្រុកវិញស្លាប់ម្នាក់ ។

ប៊ុនថនៈ បាទ ។

នាវៈ កាលទៅធ្វើទាហាននៅកំពង់សោមស្លាប់ម្នាក់ទៀត ហើយម្នាក់ទៀតស្លាប់នៅកោះកុង ។

ប៊ុនថនៈ ចឹងមីងតាំងពីបែកផ្ទះមកមីងមាននឹកផ្ទះដែរ?

នាវៈ ជំនាន់ហ្នឹងយើងនាំគ្នាយំនឹកផ្ទះ តែផ្ទះនោះយើងមិននៅផ្ទះព្រោះអីផ្ទះយើងចឹងទៅ គេថាផ្ទះហ្នឹងត្រូវបញ្ចូលឃុំផ្សេងគេមិនឲ្យនៅទេ បើចង់នៅទៅនៅឃុំផ្សេងហើយយើងចុះពីផ្ទះហ្នឹងមក មកនៅខុម ។

ប៊ុនថនៈ បាទ ។

នាវៈ ចឹងមានផ្ទះមានអី ផ្ទះគេរុះអស់ហើយ ។

ប៊ុនថនៈ តែកាលមីងចេញមកកាល៧៨ហ្នឹងមាននឹកផ្ទះទេ?

នាវៈ នឹកដែលយំគេយកយើងទៅដាក់កោះឬស្សី កុមារកាលមកដល់កំពង់សោមដំបូងគេយកទៅកោះឬស្សី ។

ប៊ុនថនៈ យ៉ាងម៉េចបានជាគេយកទៅហ្នឹងវិញ?

នាវៈ គេយកទៅឆ្កាព្រៃដូង ។

ប៊ុនថន: បាទ ។

នាវៈ ចំការដូងគេសុទ្ធព្រៃគេឆ្កា វាពិបាកព្រៃឲ្យវាលដល់ហើយគេថាសភាពការណ៍អត់ស្រួលទេ បានគេយកឡើងមកគោក ។

ប៊ុនថន: សភាពការណ៍អត់ស្រួលយ៉ាងម៉េចមីង?

នាវៈ សភាពការណ៍អត់ស្រួលដូចថាយួនបុកមកចឹងទៅណាស់ ។

ប៊ុនថន: បាទ ។

នាវៈ ជំនាន់ហ្នឹងយួនបុកបន្តិចៗហើយជំនាន់ហ្នឹង គេយកមកគោកវិញគេឲ្យមកធ្វើចំការដូងនៅគោកវិញនេះមាត់សមុទ្រនេះវិញ ចំការដូងរៀមហ្នឹង ។

ប៊ុនថន: បាទ ។

នាវៈ ចំការដូងចេង ហេងហ្នឹង ។

ប៊ុនថន: និយាយថាទៅហ្នឹងមីងចង់មកផ្ទះដែលទេ កាលហ្នឹង?

នាវៈ ចង់តែមិនដឹងជាផ្លូវណាណាអីអត់ស្គាល់ ឆ្ងាយគេដឹកឡានមកយើងនៅតូចៗអាយុ១៥ ។

ប៊ុនថន: កាលហ្នឹងមីងនៅក្មេង?

នាវៈ ចាស ។

ប៊ុនថន: ចឹងមីងមានដែលទទួលដំណឹងពីផ្ទះទៅវិញទេ?

នាវៈ អត់ទេ តែយើងចេញចឹងអត់មានដំណឹងទេ ព្រោះអីអត់មានពីណាចេញចូល អត់មានចេញចូលទេ បាត់រហូត ។

ប៊ុនថន: ចឹងឪពុកម្ដាយមីងនៅរស់ដែរ?

នាវៈ ឪពុកស្លាប់ហើយនៅតែម្ដាយ ។

ប៊ុនថន: គាត់នៅរស់ដល់រាល់ថ្ងៃហ្នឹងនឹង?

នាវៈ ចាស ។

ប៊ុនថន: រស់នៅណាវិញ នៅស្រុកកំណើត?

នាវៈ អត់ទេ នៅកំពង់សោមនៅព្រៃនប់ ។

ប៊ុនថន: គាត់ដូរមកនៅកំពង់សោមវិញ?

នាវៈ គាត់មកនៅព្រៃនប់វិញ?

ប៊ុនថន: ចឹងមីងមានដែលទៅលេងផ្ទះដែលមីង?

នាវៈ ទៅដែលហ្នឹង ។

ប៊ុនថន៖ បានទៅច្រើនដងដែរ?

នាវ៉ៈ ចាស!មួយឆ្នាំទៅម្ដង ។

ប៊ុនថន៖ បានទៅប៉ុន្មានដងហើយ?

នាវ៉ៈ ទៅញឹកដែរ តាំងពីផ្ដាច់ខ្លួនមកឆ្នាំម្ដងៗ ។

ប៊ុនថន៖ ចឹងកាលនៅដល់ដីបូងមីងមានអារម្មណ៍យ៉ាងម៉េចមីង?

នាវ៉ៈ កាលដំបូងទៅដីបូងភ្លេចភ្លាំងអស់ហើយស្រុកទេស ។

ប៊ុនថន៖ ចឹងធ្វើម៉េចបានរកឃើញមីង?

នាវ៉ៈ ចុះយើងស្គាល់ភូមិយើងចឹងទៅ យើងចេះតែទៅ យើងទៅទៅផ្ទះបណ្ដោយ ។

ប៊ុនថន៖ តែទៅដល់ដីបូងមានអារម្មណ៍យ៉ាងម៉េចភ្ញាក់?

នាវ៉ៈ ភ្ញាក់ផ្អើលឬកំសត់ផ្ទះក៏តូចគេរុះអស់ ផ្ទះខ្ញុំមធ្លាប់ពូមុនផ្ទះធំ ដីស្រែគេចែកគ្នានៅតូចៗពីមុនដីស្រែច្រើនដែរ ។

ប៊ុនថន៖ ទៅហ្នឹងជួបប្អូនៗហ្នឹងបងនៅហ្នឹង?

នាវ៉ៈ បងប្អូននៅពីរនាក់បីនាក់ស្គាល់មីងដែលកាលទៅដីបូង ។

ប៊ុនថន៖ បាទ ។

នាវ៉ៈ យើងទៅដីបូងហ្នឹងឃើញមុខស្រដៀងៗគ្នាចេះតែស្គាល់គ្នាទៅតែប្អូនៗធំៗមកតាំងពីអាយុ៣ទៅ៤ឆ្នាំ ៦ទៅ៧ទៅគេក្រមុំកំលោះបាត់ទៀតហើយ មើលទៅស្រដៀងៗ ។

ប៊ុនថន៖ បាទ!បែកគ្នាយូរ?

នាវ៉ៈ ចាស!បែកគ្នាយូរ ។

ប៊ុនថន៖ កាលមីងទៅហ្នឹងម្ដាយនិងប្អូនមីងមិនទាន់ទៅកំពង់សោមទេ?

នាវ៉ៈ ចាស!នៅទេ ឥឡូវគេមកកំពង់សោមហើយ ។

ប៊ុនថន៖ ចឹងមីងខស្បាហ៍ទៅដែរ អ្នកភូមិមានស្គាល់មីងទេ?

នាវ៉ៈ ស្គាល់ ។

ប៊ុនថន៖ មានមកលេងអីចឹង?

នាវ៉ៈ ចាស ។

ប៊ុនថន៖ កាលភ្ជុំនេះមីងមានបានទៅដែរ?

នាវ៉ៈ អត់ ថាចាំប្រាំងនេះបានទៅ ។

ប៊ុនថន៖ ចឹងសួរមីងមួយទៀតថា កាលមុនសមាហរណ៍កម្មនិងក្រោយសមាហរណ៍កម្ម ចឹងជីវភាពក្នុងការរស់នៅអីមានលក្ខណៈខុសប្លែកគ្នាយ៉ាងម៉េចដែរ?

នាវៈ ខុសប្លែកពីមុនដូចជាច្បាប់យើងតឹងចឹងទៅណាស់ យើងអត់មានដើរហើរទៅក្នុងបានចឹងទៅណាស់ ។

ប៊ុនថន: បាទ ។

នាវៈ យើងមានតែអង្ករបេបគេចែកឲ្យប៉ុន្មានហូបប៉ុណ្ណឹងទៅ ដល់ពេលផ្ដាច់ហើយយើងដើរទៅណាក៏បានជីវភាពយើងធូរធារយើងរកស៊ីអីក៏បានចឹងទៅ ។

ប៊ុនថន: បាទ ។

នាវៈ យើងរៀងសប្បាយឃើញគេឃើញឯងចឹងទៅ ពីមានឃើញតែគ្នាឯង អត់មានទៅណាទៅណីរួច ។

ប៊ុនថន: បាទ ។

នាវៈ ឥឡូវសប្បាយណាស់ ជីវិតណាមានផ្លូវនៅដើរមានឡានជិះចឹងទៅវាស្រួល ។

ប៊ុនថន: ចឹងខ្ញុំចង់សួរមីងមួយទៀត កាលសម័យកងបដិវត្តអីមីងនៅកងចល័តអីមាននៅកងដឹកជញ្ជូន នៅកងសិល្បៈអីមីងសម័យហ្នឹងមានជួយអ្នកផ្សេងអីទេដូចថា ជួយអ្នកផ្សេងដែលអត់ដូចជាឲ្យរបបអាហារឲ្យសម្លៀកបំពាក់ឲ្យគេមានដែលទេ?

នាវៈ ឲ្យដែលជំនាន់ហ្នឹងយើងអត់មានឪពុកម្ដាយដែរ ដើរចឹងទៅគេឲ្យយើង១០ទៅ២០បាតចឹងទៅយកមកទិញសារ៉ុងទិញអីស្លៀកចឹងទៅយើងអត់នោះ ។

ប៊ុនថន: តែមីងមានដែលឲ្យអ្នកផ្សេងដែរ?

នាវៈ ចាស!ខោអាវយើងស្លៀកអត់ចុះចឹងយើងចែកឲ្យគេទៀតទៅ យើងជួយគ្នាដូចជាគេមកសុំយើងចឹងទៅចង់សុំសារ៉ុងអីយើងឲ្យ ចេះតែឲ្យគេចឹងទៅខោអាវកូនចៅស្លៀកមិនកើតអីកើបឲ្យគេអស់ទៅ ។

ប៊ុនថន: បាទ ។

នាវៈ អាណិតគេឃើញគេអត់ អត់ជាងយើង ។

ប៊ុនថន: ចឹងមីងសព្វថ្ងៃនេះមីងនៅតែមើលកូនបីនាក់ទេ?

នាវៈ ចាស!នៅជាមួយកូនបី កូនប្រសារមួយ ។

ប៊ុនថន: ចឹងពូទៅសៀមរាបប៉ុន្មានខែគាត់មកផ្ទះម្ដង?

នាវៈ គាត់មិនទៀងទេ គាត់ទៅធ្វើការក្រុមហ៊ុន ជួនបីបួនខែមួយខែពីរខែចឹង គាត់នៅទាហានគាត់ឈប់ពីទាហានគាត់នៅធ្វើការក្រុមហ៊ុន ។

ប៊ុនថន: ចឹងមីងមានអ៊ីចង់បន្ថែមទេ ដូចថាមានអ៊ីចងចាំជាងគេកាលសម័យខ្មែរក្រហម មីងគិតថាមីងមានអនុស្សាវរីយ៍អីដែលមីងនៅចងចាំ?

នារ៉ៈ មានអនុស្សាវរីយ៍អី មានតែលំបាកវេទនាជំនាន់ហ្នឹង ។

ប៊ុនថនៈ ពិបាកយ៉ាងម៉េចទៅ?

នារ៉ៈ ហូបបបរមួយវែកជាមួយសម្លប្រលិត មួយវែកចឹងមកចែកបបរគ្នាបីវែកហត់តែទឹកៗអត់មានកាកជំនាន់ហ្នឹងដូចជាមិនភ្លេចចឹងទៅណាស់ ។

ប៊ុនថនៈ បាទ ។

នារ៉ៈ យើងមានប្រវត្តដូរចត់ ។

ប៊ុនថនៈ មីងតែប៉ុណ្ណឹងទេមីង?

នារ៉ៈ ចាស ។

ប៊ុនថនៈ ចឹងខ្ញុំដូចជាអស់អីសួរមីងដែរ?

នារ៉ៈ ចាស ។

ប៊ុនថនៈ អរគុណច្រើន ។

នារ៉ៈ ចាស ។

**«ចប់»**